## សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## ស្តីពីការពិគ្រោះយោបល់លើការកំណត់បញ្ជីថ្លៃលក់អគ្គិសនី តាមយន្តការកែតម្រូវថ្លៃលក់តាមថ្លៃប្រេងម៉ាស៊ូតឱ្យសេវាករ សេង ជិនលាង និងសេវាករ ប៉ាត់ ស៊ាងហ៊ុន ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ទូទៅ នៅឃុំព្រៃកពោធិ៍ ស្រុកស្រីសន្ធរ និងនៅទីរួមស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជំរាបជូនសាធារណជនដែលជាអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់សេវាករ សេង ជិនលាង និងសេវាករ ប៉ាត់ ស៊ាងហ៊ុន ឱ្យបានជ្រាបថា ដោយសារស្ថានភាពតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារមានភាពប្រែប្រួលឡើងចុះឥតទៀងទាត់ និងដើម្បីកំណត់បញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករធ្វើសេវាកម្មអគ្គិសនីមានអត្រាថ្លៃលក់ត្រឹមត្រូវ និងយុត្តិធម៌ អាជ្ញាធរអគ្គិសនីកម្ពុជាបានចាត់តាំងមន្ត្រីជំនាញចុះទៅកាន់ទីតាំងធ្វើសេវាកម្មអគ្គិសនីរបស់សេវាករទាំង២ ដើម្បីពិនិត្យវាស់អត្រាប្រើប្រាស់ប្រេង បរិមាណថាមពលផលិត និងប្រមូលទិន្នន័យពាក់ព័ន្ធនឹងការធ្វើសេវាកម្មអគ្គិសនី ដោយបានអញ្ជើញតំណាងសាលាឃុំ និងតំណាងអ្នកប្រើប្រាស់នៅក្នុងតំបន់របស់សេវាករទាំង២ចូលរួមជាអ្នកអង្កេតការណ៍ រួចយកមកធ្វើការសិក្សាថ្លៃដើមអគ្គិសនី និងកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ការធ្វើសេវាកម្មអគ្គិសនីនេះ ស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី ។ តាមស្ថានភាពតម្លៃប្រេងម៉ាស៊ូតនៅលើទីផ្សារមានភាពប្រែប្រួលឡើងចុះឥតទៀងទាត់ ដូច្នេះ ដើម្បីធានានិរន្តភាពនៃការផ្គត់ផ្គង់អគ្គិសនី និងស្ថានភាពហិរញ្ញវត្ថុរបស់សេវាករទាំង២ និងដើម្បីឱ្យមានយុត្តិធម៌ និងសមធម៌ រវាងអ្នកប្រើប្រាស់អគ្គិសនី និងអ្នកធ្វើសេវាកម្មផង អាជ្ញាធរអគ្គិសនីកម្ពុជាបានគណនាថ្លៃដើមអគ្គិសនី និងគ្រោងកំណត់បញ្ជីថ្លៃលក់អគ្គិសនីប្រែប្រួលតាមថ្លៃប្រេងម៉ាស៊ូត ដូចក្នុងតារាងខាងក្រោម ÷

| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **360** | **425** | **490** | **555** | |
|---|---|---|---|---|---|
| ថ្លៃដើមអគ្គិសនីសេវាករ សេង ជិនលាង (រៀល/គ.វ.ម៉) | 1,438 | 1,546 | 1,654 | 1,762 | |
| ថ្លៃដើមអគ្គិសនីសេវាករ ប៉ាត់ ស៊ាងហ៊ុន (រៀល/គ.វ.ម៉) | 1,394 | 1,499 | 1,604 | 1,709 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **1,800** | **1,900** | **2,000** | **2,100** | |

| | | | | | |
|---|---|---|---|---|---|
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **620** | **685** | **750** | **815** | |
| ថ្លៃដើមអគ្គិសនីសេវាករ សេង ជិនលាង (រៀល/គ.វ.ម៉) | 1,870 | 1,978 | 2,086 | 2,195 | |
| ថ្លៃដើមអគ្គិសនីសេវាករ ប៉ាត់ ស៊ាងហ៊ុន (រៀល/គ.វ.ម៉) | 1,815 | 1,920 | 2,025 | 2,130 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **2,200** | **2,300** | **2,400** | **2,500** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **880** | **945** | **1,010** | **1,075** | |
| ថ្លៃដើមអគ្គិសនីសេវាករ សេង ជិនលាង (រៀល/គ.វ.ម៉) | 2,303 | 2,411 | 2,519 | 2,627 | |
| ថ្លៃដើមអគ្គិសនីសេវាករ ប៉ាត់ ស៊ាងហ៊ុន (រៀល/គ.វ.ម៉) | 2,235 | 2,341 | 2,446 | 2,551 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **2,600** | **2,700** | **2,800** | **2,900** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **1,140** | **1,205** | **1,270** | **1,335** | |
| ថ្លៃដើមអគ្គិសនីសេវាករ សេង ជិនលាង (រៀល/គ.វ.ម៉) | 2,735 | 2,843 | 2,952 | 3,060 | |
| ថ្លៃដើមអគ្គិសនីសេវាករ ប៉ាត់ ស៊ាងហ៊ុន (រៀល/គ.វ.ម៉) | 2,656 | 2,762 | 2,867 | 2,972 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **3,000** | **3,100** | **3,200** | **3,300** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **1,400** | **1,465** | **1,530** | **1,595** | |
| ថ្លៃដើមអគ្គិសនីសេវាករ សេង ជិនលាង (រៀល/គ.វ.ម៉) | 3,168 | 3,276 | 3,384 | 3,492 | |
| ថ្លៃដើមអគ្គិសនីសេវាករ ប៉ាត់ ស៊ាងហ៊ុន (រៀល/គ.វ.ម៉) | 3,077 | 3,183 | 3,288 | 3,393 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **3,400** | **3,500** | **3,600** | **3,700** | |
| **ថ្លៃប្រេងម៉ាស៊ូត (ដុល្លារអាមេរិក/តោន)** | **1,660** | **1,725** | **1,790** | **1,855** | |
| ថ្លៃដើមអគ្គិសនីសេវាករ សេង ជិនលាង (រៀល/គ.វ.ម៉) | 3,600 | 3,709 | 3,817 | 3,925 | |
| ថ្លៃដើមអគ្គិសនីសេវាករ ប៉ាត់ ស៊ាងហ៊ុន (រៀល/គ.វ.ម៉) | 3,498 | 3,603 | 3,709 | 3,814 | |
| **ថ្លៃលក់អគ្គិសនី (រៀល/គ.វ.ម៉)** | **3,800** | **3,900** | **4,000** | **4,100** | |

តាមតារាងខាងលើ នៅពេលថ្លៃប្រេងម៉ាស៊ូតឡើងថ្លៃ ឬចុះថ្លៃតាមចំនួនកំណត់ក្នុងតារាងខាងលើ ពេលនោះ អត្រាថ្លៃលក់អគ្គិសនីរបស់សេវាករទាំង២អាចឡើង ឬចុះតាមចំនួនកំណត់ក្នុងតារាងខាងលើ ។

ដើម្បីឱ្យមានតម្លាភាព អាជ្ញាធរអគ្គិសនីកម្ពុជាស្នើសុំឱ្យក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងសាធារណជនទាំងអស់មេត្តាពិនិត្យ និងផ្តល់មតិលើឯកសារគណនា វិភាគ វាយតម្លៃកំណត់បញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករទាំង២ ជាតារាងថ្លៃលក់តាមថ្លៃប្រេងម៉ាស៊ូត ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០**។ ក្រោយថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០ ឯកសារគណនា វិភាគវាយតម្លៃបញ្ជីថ្លៃលក់អគ្គិសនីឱ្យសេវាករទាំង២ នឹងត្រូវចាត់ទុកថាបានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជានឹងអាចធ្វើការពិនិត្យ និងអនុម័តលើតារាងបញ្ជីថ្លៃលក់នេះ ទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរសុំឱ្យ **ការផ្តល់យោបល់មកឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា មានមូលដ្ឋានសំអាងគ្រប់គ្រាន់ និងអាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៩៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ហើយសូមឱ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាពឱ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់ផង និងអ្នកធ្វើសេវាកម្មអគ្គិសនីផង**។

ឯកសារស្នើសុំកំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់សេវាករទាំង២ ឯកសារគណនា វិភាគ វាយតម្លៃថ្លៃដើមអគ្គិសនី តារាងបញ្ជីថ្លៃលក់អគ្គិសនីតាមថ្លៃប្រេងម៉ាស៊ូតលម្អិត ព្រមទាំងល័ក្ខខ័ណ្ឌសម្រាប់អនុវត្តយន្តការកំណត់បញ្ជីថ្លៃលក់អគ្គិសនីតាមថ្លៃប្រេងម៉ាស៊ូត ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យ លេខ៩៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ មានតម្កល់ទុកនៅ.......................................................................................... សម្រាប់សាធារណជនទាំងអស់ដែលមានចំណាប់អារម្មណ៍ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ មេត្តាជ្រាបជាពត៌មាន។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**